# ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច ផ្នែកទី ១



គោលបំណងខ្ញុំនៅយប់នេះគឺត្រូវឲ្យប្រាកដថា ក្មួយៗយល់ច្បាស់អំពីសេចក្តីពិតដែលថា ជីវិតនេះ *គឺ* ពិតជាពេលវេលាដែលក្មួយៗត្រូវសម្រេចចិត្តថា តើជីវិតបែបណាដែល *ក្មួយៗ* ចង់រស់នៅជារៀងរហូតនោះ ។ ឥឡូវនេះ *គឺជា* ពេលវេលារបស់ក្មួយៗ « ប្រុងប្រៀបទៅជួបព្រះ » [ សូមមើល អាលម៉ា ១២:២៤; ៣៤:៣២ ] ។ . . .

រាល់ការជ្រើសរើសសុចរិតដែលក្មួយៗធ្វើនៅទីនេះ នឹងទទួលបានរង្វាន់ក្នុងជីវិតនេះ ។ ប៉ុន្តែការជ្រើសរើសសុចរិតក្នុងជីវិតរមែងស្លាប់ក៏នឹងទទួលបានរង្វាន់ដ៏នៅអស់កល្បជានិច្ចដែលនឹកស្មានមិនដល់ផងដែរ ។ បើក្មួយៗជ្រើសរើសចុះសេចក្តីសញ្ញានឹងព្រះ ហើយស្មោះត្រង់ចំពោះសេចក្តីសញ្ញាទាំងនោះ នោះក្មួយៗមាននូវការសន្យានៃ « សិរីល្អបន្ថែមទៅលើក្បាល [ ក្មួយៗ ] ជារៀងដរាបរហូតតទៅ » [ អ័ប្រាហាំ ៣:២៦] ។ . . .

ជាការពិតណាស់ មារសត្រូវមិនចង់ឲ្យក្មួយៗគិតសូម្បីតែអំពីថ្ងៃស្អែក ចុះទម្រាំជីវិតដ៏នៅអស់កល្បជានិច្ចទៀតនោះ ។ ប៉ុន្តែសូមកុំអវិជ្ជា ឬធោតល្ងង់អំពីឱកាស និងការប្រឈមនានានៃជីវិតរមែងស្លាប់នេះឡើយ ។ នៅក្នុងស្មារតីនោះ ក្មួយៗត្រូវយល់អំពីសេចក្តីពិតជាមូលដ្ឋានចំនួនបី ដែលនឹងជួយក្មួយៗឲ្យរៀបចំខ្លួនសម្រាប់ទិសដៅនៅពេលអនាគត ៖ . . .

ទីមួយ ៖ ស្គាល់សេចក្តីពិតថាក្មួយៗជានរណា ។ ខ្ញុំជឿថា បើព្រះអម្ចាស់មានបន្ទូលទៅកាន់ក្មួយៗដោយផ្ទាល់នៅរាត្រីនេះ រឿងដំបូងដែលទ្រង់ច្បាស់ជាឲ្យក្មួយៗយល់គឺអំពីអត្តសញ្ញាណដ៏ពិតប្រាកដរបស់ក្មួយៗ ។ ឱ ក្មួយៗជាទីស្រឡាញ់ ក្មួយៗគឺជាបុត្រាបុត្រីខាងវិញ្ញាណរបស់ព្រះពិតប្រាកដមែន ។ ក្មួយៗបានច្រៀងអំពីសេចក្តីពិតនេះ ចាប់តាំងពីក្មួយៗបានរៀនបទ « ខ្ញុំជាកូនរបស់ព្រះ » [ *ទំនុកតម្កើង* ល.រ. ១៨៨ ] ។ ប៉ុន្តែតើសេចក្តីពិតដ៏នៅអស់កល្បនោះបានដក់ជាប់ក្នុងដួងចិត្តក្មួយៗហើយឬនៅ ? តើសេចក្តីពិតនេះបានសង្គ្រោះក្មួយៗ កាលដែលក្មួយៗប្រឈមមុខនឹងការល្បួងដែរឬទេ ?

ខ្ញុំខ្លាចថា ក្មួយៗអាចស្តាប់ឮសេចក្តីពិតនេះញឹកញាប់ពេក រហូតដល់វាដូចជាពាក្យស្លោក ជាជាងសេចក្តីពិតដ៏ទេវភាព ។ ប៉ុន្តែរបៀបដែលក្មួយៗគិតថាក្មួយៗជានរណាឲ្យពិត ជះឥទ្ធិពលស្ទើរតែគ្រប់ការសម្រេចចិត្តដែលក្មួយៗធ្លាប់ធ្វើ ។ . . .

*. . .តើក្មួយៗជានរណា ?*

ដំបូង ហើយសំខាន់បំផុត ក្មួយៗគឺជាបុត្ររបស់ព្រះ ។

ទីពីរ ក្នុងនាមជាសមាជិកសាសនាចក្រ ក្មួយៗគឺជាបុត្រនៃសេចក្តីសញ្ញា ។ និងទីបី ក្មួយៗគឺជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។

យប់នេះ ខ្ញុំសូមអង្វរក្មួយៗកុំឲ្យ *ជំនួស* អត្តសញ្ញាណដ៏ខ្ពង់ខ្ពស់ និងពុំផ្លាស់ប្តូរទាំងបីនេះ ជាមួយនឹងងារណាមួយផ្សេងទៀតឲ្យសោះ ដោយសារការធ្វើបែបនោះអាចរារាំងដល់ការរីកចម្រើនរបស់ក្មួយៗ ឬវាដាក់ក្មួយៗទៅក្នុងក្រុមមួយដែលអាចរាំងស្ទះដល់ការរីកចម្រើនដ៏នៅអស់កល្បជានិច្ចរបស់ក្មួយៗ ។ . . .

ពិតណាស់ វាអាចនឹងមានស្លាកផ្សេងៗដែលមានសារៈសំខាន់ខ្លាំងចំពោះក្មួយៗ ។ សូមកុំយល់ខុសពីការលើកឡើងរបស់ខ្ញុំឡើយ ។ ខ្ញុំពុំមែននិយាយថា ងារ និងអត្តសញ្ញាណមិនសំខាន់នោះទេ ។ ខ្ញុំគ្រាន់តែនិយាយថា ពុំគួរមានអត្តសញ្ញាណណាមួយដែលគួរមក *ប្តូរ ជំនួស* ឬ *មានអាទិភាពខ្លាំងជាង* ងារដ៏និរន្តរ៍ទាំងបីនេះឡើយ រួមមាន ៖ « បុត្រនៃព្រះ » « បុត្រនៃសេចក្តីសញ្ញា » និង « សិស្សនៃព្រះយេស៊ូវគ្រីស្ទ » ។

អត្តសញ្ញាណណាមួយដែលមិនសមស្របនឹងងារជាគោលទាំងបីនេះ នឹងធ្វើឲ្យក្មួយអស់សង្ឃឹមនៅទីបំផុត ។ ងារផ្សេងទៀតនឹងធ្វើឲ្យក្មួយខកចិត្តពេលណាមួយដោយសារវាគ្មានអំណាចដឹកនាំក្មួយទៅរកជីវិតដ៏នៅអស់កល្បជានិច្ចនៅក្នុងនគរសេឡេស្ទាលរបស់ព្រះបានឡើយ ។ . . .

ពិតណាស់ ៖ សក្តានុពលរបស់ក្មួយៗគឺទេវភាព ។ តាមការខិតខំស្វែងរកដ៏ឧស្សាហ៍របស់ក្មួយ នោះព្រះនឹងបំភ្លឺអំពីបុគ្គលដែលក្មួយនឹងប្រែក្លាយ ។ ( រ័សុល អិម ណិលសុន « ការជ្រើសរើសដែលជះឥទ្ធិពលលើភាពអស់កល្បជានិច្ច » [ ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់ យុវមជ្ឈិមវ័យ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២២ ] នៅលើគេហទំព័រ broadcasts.ChurchofJesusChrist.org )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_544_handout-1